County of Los Angeles
DEPARTMENT OF
PUBLIC SOCIAL SERVICES

Medi-Cal

# ការផ្លាស់ប្តូរថ្មីទៅលើច្បាប់ទ្រព្យសម្បត្តិសម្រាប់កម្មវិធី Medi-Cal នោះមានន័យថាមនុស្សកាន់តែច្រើនអាចរក្សាការធានារ៉ាប់រងសុខភាពរបស់ពួកគេ ។

## ច្បាប់ថ្មីមានន័យថាទ្រព្យសម្បត្តិនឹងមិនត្រូវបានរាប់បញ្ចូលសម្រាប់កម្មវិធី Medi-Cal ទេ



- ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ទ្រព្យសម្បត្តិមិនត្រូវបានរាប់បញ្ចូលទៅក្នុងសិទ្ធិទទួលបានកម្មវិធី Medi-Cal ទៀតទេ ។
- **អ្នកមិនចាំបាច់**រាយការណ៍អំពីទ្រព្យសម្បត្តិដូចជាគណនីធនាគារ អចលនទ្រព្យ និងយានយន្តទេ ។
- សំណៅដាក់ពាក្យស្នើសុំ និងសំណៅការកំណត់ឡើងវិញប្រចាំឆ្នាំនឹងមិនមានសួររកព័ត៌មានអំពីទ្រព្យសម្បត្តិទៀតទេ ។
- ប្រាក់ចំណូលដែលបានទទួលពីអចលនទ្រព្យដូចជាចំណូលពីការជួលផ្ទះ ឬការប្រាក់បានមកពីគណនីធនាគារនឹងបន្តត្រូវបានរាប់ចូលជាប្រាក់ចំណូល ។



## អ្នកអាចដាក់ពាក្យស្នើសុំកម្មវិធី Medi-Cal:

- **ដោយជួបផ្ទាល់** - ចូលទៅកាន់ការិយាល័យ Medi-Cal ក្នុងតំបន់របស់អ្នក ។
- **តាមអនឡាញ** - ចូលក្នុងបណ្តាញ ឬបង្កើតគណនីជាមួយ BenefitsCal.com
- **តាមសំបុត្រ** - ផ្ញើទៅអាសយដ្ឋាននៅលើសំណៅរបស់អ្នក ។
- **តាមរយៈទូរស័ព្ទ** - ទូរស័ព្ទទៅមជ្ឈមណ្ឌលសេវាកម្មអតិថិជននៅលេខ (866)613-3777

# ការលុបបំបាត់ទ្រព្យសម្បត្តិសំរាប់កម្មវិធី Medi-Cal
# សំណួរ និងចម្លើយដែលសួរជាញឹកញាប់

## ➢ តើទ្រព្យសម្បត្តិប៉ះពាល់ដល់សិទ្ធិទទួលបានរបស់ខ្ញុំដែរ ឬទេ?

- **ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024** ទ្រព្យសម្បត្តិដូចជាគណនីធនាគារ សាច់ប្រាក់ រថយន្តទីពីរ និងផ្ទះនឹងមិនត្រូវបានរាប់បញ្ចូលទៀតទេ នៅពេលកំណត់សិទ្ធិទទួលបានកម្មវិធី Medi-Cal ។ ប្រាក់ចំណូល និងប្រាក់ចំណូលពីទ្រព្យសម្បត្តិដូចជាចំណូលពីអចលនទ្រព្យនឹងបន្តត្រូវបានរាប់បញ្ចូល ។

## ➢ តើអ្វីជា "ទ្រព្យសម្បត្តិ?"

- ទ្រព្យសម្បត្តិ រួមមានគណនីធនាគារ សាច់ប្រាក់ រថយន្តទីពីរ  ផ្ទះ និងធនធានហិរញ្ញវត្ថុផ្សេងៗទៀត។

## ➢ ប្រសិនបើខ្ញុំកំពុងដាក់ពាក្យស្នើសុំកម្មវិធី Medi-Cal តើខ្ញុំត្រូវបំពេញ និងបញ្ជូនព័ត៌មានអំពីទ្រព្យសម្បត្តិដែរ ឬទេ?

- ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ការដាក់ពាក្យស្នើសុំកម្មវិធី Medi-Cal នឹងមិនសាកសួររកព័ត៌មានអំពីទ្រព្យសម្បត្តិទៀតទេ។
- ព័ត៌មានអំពីទ្រព្យសម្បត្តិ និងភ័ស្តុតាងបញ្ជាក់គឺត្រូវបានទាមទារ ប្រសិនបើអ្នកកំពុងស្នើសុំការធានារ៉ាប់រង Medi-Cal សម្រាប់ឆ្នាំ 2023 ។
- ចាប់ពីខែមករា ឆ្នាំ 2024 បុគ្គលដែលដាក់ពាក្យស្នើសុំសេវាសម្រាប់ថែទាំរយៈពេលយូរអង្វែង (LTC) អាចត្រូវបានតម្រូវឱ្យផ្តល់ការបញ្ជាក់ទ្រព្យសម្បត្តិ ប្រសិនបើក្នុងរយៈពេល 30 ខែចុងក្រោយនេះ ទ្រព្យសម្បត្តិត្រូវបានផ្ទេរសម្រាប់ចំនួនតិចជាងតម្លៃត្រឹមត្រូវលើទីផ្សារ ។

## ➢ ប្រសិនបើខ្ញុំជាសមាជិកទទួលបានកម្មវិធី Medi-Cal បច្ចុប្បន្ន តើខ្ញុំត្រូវបំពេញ និងបញ្ជូនព័ត៌មានអំពីទ្រព្យសម្បត្តិនៅពេលការកំណត់ឡើងវិញប្រចាំឆ្នាំដែរ ឬទេ?

- ទេ ព័ត៌មានទ្រព្យសម្បត្តិមិនត្រូវបានទាមទារទេ។
- នៅឆ្នាំ 2024 សំណៅការកំណត់ឡើងវិញប្រចាំឆ្នាំនឹងមិនសួររកព័ត៌មានទ្រព្យសម្បត្តិទៀតទេ។
- នោះមានន័យថាអ្នកអាចរក្សាការសន្សំ និងទ្រព្យសម្បត្តិរបស់អ្នក ហើយនៅតែរក្សាការធានារ៉ាប់រង Medi-Cal របស់អ្នកបាន។
- វាមានសារៈសំខាន់ណាស់ក្នុងការបើក និងពិនិត្យឡើងវិញនូវសំបុត្រណាមួយដែលបានទទួលពីខោនធីរបស់អ្នកអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក។

- **ខ្ញុំមិនមានសិទ្ធិទទួលបានពីមុន។ ជាមួយនឹងការផ្លាស់ប្តូរទាំងនេះ តើឥឡូវនេះខ្ញុំអាចនឹងទទួលបានដែរ ឬទេ?**
  - បាទ/ចាស។ ប្រសិនបើអ្នកជឿថាអ្នកអាចមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ជាមួយនឹងការផ្លាស់ប្តូរទ្រព្យសម្បត្តិ សូមស្វែងយល់បន្ថែម និងដាក់ពាក្យស្នើសុំនៅគេហទំព័រ GetMedi-CalCoverage.dhcs.ca.gov.

- **តើខ្ញុំអាចទទួលបានជំនួយក្នុងការបំពេញសំណៅដែរ ឬទេ?**
  - មានជំនួយ។ សម្រាប់ជំនួយ សូមទាក់ទងទៅ មជ្ឈមណ្ឌលសេវាកម្មអតិថិជន របស់យើងតាមលេខ (866) 613-3777 ។

- **ចុះបើខ្ញុំមិនមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ទៀតទេ?**
  - ប្រសិនបើការធានារ៉ាប់រងរបស់អ្នកត្រូវបានបដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ឈប់ អ្នកអាចស្នើសុំឱ្យការិយាល័យកម្មវិធី Medi-Cal ក្នុងតំបន់របស់អ្នក ពិនិត្យឡើងវិញនូវសំណុំរឿងរបស់អ្នក។ អ្នកក៏អាចស្នើសុំឱ្យមានសវនាការយុត្តិធម៌រដ្ឋដើម្បីកំណត់សិទ្ធិទទួលបានរបស់អ្នក ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តនេះ។ ដាក់សុំ ការស្នើសុំតាមអនឡាញ នៅទីនេះ ឬទូរស័ព្ទទៅអង្គភាពផ្នែកសវនាការរដ្ឋ តាមលេខឥតគិតថ្លៃ (800) 743-8525 ។ ប្រសិនបើអ្នកស្នើសុំសវនាការមុនពេលកម្មវិធី Medi-Cal របស់អ្នកបញ្ចប់ ការធានារ៉ាប់រងរបស់អ្នកនឹងបន្តក្នុងអំឡុងពេលដំណើរការ។

- **ចុះប្រសិនបើខ្ញុំត្រូវបានស្នើសុំឱ្យបង់ប្រាក់ដើម្បីបំពេញពាក្យស្នើសុំការកំណត់ឡើងវិញប្រចាំឆ្នាំរបស់ខ្ញុំ?**
  - សូមប្រយ័ត្នពីការបោកប្រាស់៖ កម្មវិធី Medi-Cal នឹងមិនតម្រូវឱ្យបង់ប្រាក់ដើម្បីដាក់ស្នើសុំការកំណត់ឡើងវិញប្រចាំឆ្នាំ ឬដាក់ពាក្យស្នើសុំនោះទេ។ ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទសុំឱ្យបង់ប្រាក់ដើម្បីដាក់ពាក្យស្នើសុំ ឬការកំណត់ឡើងវិញប្រចាំឆ្នាំ សូមរាយការណ៍ពីរឿងនេះ។ សូមទូរស័ព្ទទៅលេខទូរស័ព្ទពិសេសផ្នែកការក្លែងបន្លំជំនួយ Medi-Cal នៅលេខ 1-800-822-6222។

- **តើមានជម្រើសអ្វីផ្សេងទៀតសម្រាប់ការធានារ៉ាប់រងឬទេ ប្រសិនបើខ្ញុំមិនមានសិទ្ធិទទួលបានកម្មវិធី Medi-Cal តទៅទៀត?**
  - ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ការិយាល័យកម្មវិធី Medi-Cal ក្នុងតំបន់របស់អ្នកនឹងបញ្ជូនព័ត៌មានរបស់អ្នកទៅកាន់ ការធានារ៉ាប់រងសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ាដែលនឹងជ្រើសរើសគម្រោងសុខភាពដែលមានគុណភាពសំរាប់អ្នក ដែលផ្តល់តម្លៃល្អបំផុតក្នុងការចំណាយទាបបំផុត។
  - ពិនិត្យមើលសំបុត្ររបស់អ្នកសំរាប់ការទំនាក់ទំនងសំខាន់ៗពីគម្រោងការធានារ៉ាប់រងសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ា រួមទាំងស្រោមសំបុត្រដែលសរសេរថា "នៅតែស្ថិតក្នុងគម្រោងការធានារ៉ាប់រងសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ា"។ ប្រសិនបើអ្នកទទួលបានការជូនដំណឹងដែលសុំឱ្យបញ្ជាក់គម្រោងរបស់អ្នក សូមឆ្លើយតបភ្លាមៗ។ អ្នកនឹងមានជម្រើសក្នុងការផ្លាស់ប្តូរគម្រោងរបស់អ្នក ឬលុបចោល។ សូមចូលទៅកាន់ CoveredCA.com ឬទូរស័ព្ទទៅមជ្ឈមណ្ឌលសេវាកម្មផ្នែកគម្រោងការធានារ៉ាប់រងសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ាតាមរយៈលេខ (800) 300-1506 ដើម្បីឱ្យបានដឹងព័ត៌មានបន្ថែម។
  - ប្រសិនបើអ្នកមាន Medicare អ្នកប្រហែលជាមិនមានលក្ខណៈសម្បត្តិទទួលបានគម្រោងការធានារ៉ាប់រងសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ាទេ។ សម្រាប់ជំនួយបន្ថែម អ្នកអាចទូរស័ព្ទទៅសម្ព័ន្ធអ្នកប្រើប្រាស់ខាងសុខភាព (Health Consumer Alliance) នៅ 1-888-804-3536 ។

- **តើកូនរបស់ខ្ញុំអាចមានសិទ្ធិបានដែរឬទេ ប្រសិនបើខ្ញុំមិនមានសិទ្ធិទទួលបាន Medi-Cal ទៀតទេ?**
    - ទោះបីជាអ្នកមិនមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ក៏ដោយ កូនរបស់អ្នកនៅតែអាចមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាព។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅ មជ្ឈមណ្ឌលសេវាកម្មអតិថិជន របស់យើងតាមលេខ (866) 613-3777 ។

- **តើខ្ញុំត្រូវធ្វើអ្វីឥឡូវនេះទេ?**
    - អ្នកមិនចាំបាច់ធ្វើអ្វីឥឡូវនេះទេ លុះត្រាតែអ្នកត្រូវបានបដិសេធពីមុន ហើយអ្នកចង់ដាក់ពាក្យស្នើសុំម្តងទៀត ឬប្រសិនបើអ្នកត្រូវការបំពេញសំណៅការកំណត់ឡើងវិញប្រចាំឆ្នាំ។

- **តើខ្ញុំនឹងទទួលការស្នើសុំពីខោនធីសម្រាប់ព័ត៌មានអំពីទ្រព្យសម្បត្តិដែរ ឬទេ?**
    - អ្នកនៅតែអាចត្រូវបានស្នើសុំឱ្យផ្តល់ឯកសារផ្សេងៗដើម្បីការបញ្ជាក់ប្រាក់ចំណូលរបស់អ្នកពីអចលទ្រព្យ/ទ្រព្យសម្បត្តិ ប្រសិនបើមាន។

- **ចុះបើខ្ញុំមិនបានទទួលកញ្ចប់ព័ត៌មានការកំណត់ឡើងវិញប្រចាំឆ្នាំ?**
    - ប្រសិនបើអ្នកមិនបានទទួលកញ្ចប់ព័ត៌មានសំរាប់ការកំណត់ឡើងវិញប្រចាំឆ្នាំ សូមទាក់ទងទៅ មជ្ឈមណ្ឌលសេវាកម្មអតិថិជន របស់យើងតាមលេខ (866) 613-3777 ដើម្បីបញ្ជាក់អាសយដ្ឋានដែលយើងមានគឺត្រឹមត្រូវ ហើយស្នើសុំឱ្យគេផ្ញើមួយច្បាប់ទៀតទៅឱ្យអ្នក។

- **តើមានការផ្លាស់ប្តូរកម្មវិធីដំណើរការឡើងវិញនៃអចលនទ្រព្យដែរ ឬទេ?**
    - មិនមានការផ្លាស់ប្តូរចំពោះកម្មវិធីដំណើការឡើងវិញនៃអចលនវត្ថុដោយសារតែការលុបបំបាត់ទ្រព្យសម្បត្តិ។ សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីដំណើការឡើងវិញនៃអចលនវត្ថុ សូមមើលគេហទំព័រ៖ Estate Recovery (ca.gov)